ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០៩
ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦
សំណុំរឿងស៊ើបសួរលេខ: ៤៣០ អ.ខ
ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧
សំណុំរឿងជំនុំជម្រះលេខ: ៧១៧
ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១
សាលក្រមលេខ: ៥៥/០៥ (ក)
ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២
ថ្ងៃអង្គារ ៨រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះសីហនុ

បានឃើញ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

បានឃើញ ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ ៦២៧៤ តពរ/២១ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ ។

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តព្រះសីហនុ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក ដែលមានសមាសភាពចូលរួម ៖

## ចៅក្រមជំនុំជម្រះ

-ឯកឧត្តម [redacted] ជាប្រធានសាលាដំបូង

## តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារង

## ក្រឡាបញ្ជីសវនាការ

-លោក [redacted] ជាក្រឡាបញ្ជី

**<u>ដើម្បីជំនុំជម្រះ</u> ៖**

សំណុំរឿងព្រហ្មទណ្ឌលេខ: ០៩ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ដែលមានជនជាប់ចោទ ៖

១.ឈ្មោះ [redacted] ដេង ភេទប្រុស កើតឆ្នាំ១៩៦៥ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តព្រះសីហនុ ។

ត្រូវបានចេញដីកាបង្គាប់ឱ្យចូលខ្លួនលេខ ២២៩១ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ ។

២.ឈ្មោះ [redacted]ធី ភេទស្រី ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូ[redacted] ខេត្តព្រះសីហនុ ។





Scanned with CamScanner

ត្រូវបានចេញដីកាបង្គាប់ឱ្យចូលខ្លួនលេខ ៤៤៩២ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ ។

ត្រូវបានចោទប្រកាន់ពីបទ ធ្វើឱ្យខូចខាតដោយចេតនា និងបទ រំលោភកាន់កាប់អចលនវត្ថុអ្នកដទៃ ប្រព្រឹត្តនៅចំណុចភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៦ និងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

**<u>មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ</u>**

១.លោកមេធាវី [redacted] មានអាសយដ្ឋានផ្ទះលេខ៣០១A ផ្លូវលេខ២៧១ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ (អវត្តមាន)

២.លោកមេធាវី [redacted] មានការិយាល័យក្រុមមេធាវីការពារសិទ្ធិ ស្ថិតនៅអគារលេខ៦១ ផ្លូវលេខ៦០៦ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៣.លោកមេធាវី [redacted] អត្តលេខ [redacted] មានការិយាល័យមេធាវី [redacted] ស្ថិតនៅផ្ទះលេខ ០០១ H ផ្លូវ៤៣ ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

**<u>ដើមបណ្តឹងរដ្ឋប្បវេណី</u>**

១.ឈ្មោះ [redacted] **សេដ្ឋបុត្រ** ភេទប្រុស កើតឆ្នាំ១៩៩២ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នក្រុមទី១២ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ (អវត្តមាន)

២.ឈ្មោះ [redacted] **ឌិន** ភេទប្រុស កើតឆ្នាំ១៩៦៤ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ១ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ (អវត្តមាន)

**<u>មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីៈ</u>**

១.លោកមេធាវី [redacted] មានអាសយដ្ឋាននៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ (អវត្តមាន)

២.លោកមេធាវី [redacted] មានការិយាល័យស្ថិតនៅភូមិគ្រឹះលេខ ៤២ ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។ (អវត្តមាន)

## ១.អង្គហេតុនៃបណ្តឹងចោទប្រកាន់

កាលពីឆ្នាំ១៩៩១ ឈ្មោះ [redacted] ដេង និងប្រពន្ធឈ្មោះ [redacted] ជី បានមករស់នៅភូមិអូរត្រេះ ហើយក៏បានសុំដីពីមេភូមិអូរត្រេះកាន់កាប់ និងស្នាក់នៅរហូតដល់ឆ្នាំ២០០៧ អ្នកទាំងពីរក៏បានធ្វើប្លង់ចុះបញ្ជីជាប្រព័ន្ធ ដោយសម្តេចនាយករដ្ឋមន្ត្រីបានចេញបញ្ជាលេខ ០១ ឱ្យវាស់វែងជូនប្រជាជន ពេលនោះគ្រួសារអ្នកទាំងពីរក៏បានអាជ្ញាធរមូលដ្ឋានវាស់វែងឱ្យដែរ ។ ពេលនោះដែរមានលោកឧកញ៉ា [redacted] ទ្រីវ បានដាក់ពាក្យបណ្តឹងទៅការិយាល័យ

ភូមិបាលក្រុងព្រះសីហនុ ហាមឃាត់មិនឱ្យចេញប័ណ្ណកម្មសិទ្ធិ ហើយនៅឆ្នាំ២០១៥ ឈ្មោះ [redacted] ផុំ , ឈ្មោះ [redacted] សាយ និងឈ្មោះ [redacted] វ៉ុង បានមកអះអាងថា ពួកគាត់អាចឱ្យលោកឧកញ៉ា [redacted] ទ្រី ដកពាក្យបណ្ដឹងបាន ដោយឱ្យឈ្មោះ [redacted] ធី និងឈ្មោះ [redacted] ដេង កាត់ដីឱ្យពួកគាត់ក្នុងម្នាក់ ក្បាល ១០ ម៉ែត្រ បណ្ដោយ ៣០ ម៉ែត្រ រួចឈ្មោះ [redacted] ដេង ក៏បានផ្ដិតមេដៃលក់ផ្ដាច់ឱ្យឈ្មោះ [redacted] សេដ្ឋបុត្រ ដែលត្រូវជាកូនរបស់ឈ្មោះ [redacted] ផុំ ចំនួន ០១ ឡូតិ៍ , ឈ្មោះ [redacted] សាយ ចំនួន ០១ ឡូតិ៍ និងឈ្មោះ [redacted] វ៉ុង ចំនួន ០១ ឡូតិ៍ តែអ្នកទាំងបីមិនបានដោះស្រាយជាមួយលោកឧកញ៉ា [redacted] ទ្រី ទេ ។ រហូតដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០១៦ ឈ្មោះ [redacted] ដេង និងប្រពន្ធឈ្មោះ [redacted] ធី បានទៅរៀបចំរុះរបងឈើ និងដាក់បង្គោលថ្មវិញ ហើយភាគីដើមចោទក៏បានថត និងប្ដឹងមកតុលាការតែម្ដង ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខៈ ៤៣២៤ តព/២១ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ ។

## ២. នាពេលសវនាការ

**២.១ ការស្ដាប់ចម្លើយរបស់ជនជាប់ចោទ:**

*២.១.១ ជនជាប់ចោទឈ្មោះ [redacted] ដេង បានឆ្លើយថាៈ* ខ្លួនមានអាយុ ៥៧ឆ្នាំ ។ ឈ្មោះ [redacted] ឌិន ជាបងបង្កើតរបស់ខ្លួន ។ ខ្លួនស្គាល់ឈ្មោះ សេដ្ឋបុត្រ ។ ដីនោះខ្លួនកាន់កាប់តាំងពីឆ្នាំ១៩៩២ ក្រោយមកខ្លួនបានរុះរើបង្គោលរបងលួសឈើធ្វើជារបងថ្មវិញ ហើយឈ្មោះ [redacted] ឌិន ក៏មកធ្វើរបងនៅក្នុងរបងរបស់ខ្លួនដែរ ។ ខ្លួនពិតជាបានដករបងមែន ប៉ុន្តែរបងនោះ គឺជារបងរបស់ខ្លួនទេ ។ ដំបូងខ្លួនធ្វើបង្គោលរបងឈើ បន្ទាប់មកធ្វើបង្គោលរបងស៊ីម៉ងវិញ ។ បង្គោលរបងជារបស់ខ្លួនដែលខ្លួនរើចេញនោះ ពេលនោះប្រពន្ធខ្លួនរើជាមួយគ្នា ដីជារបស់ខ្លួន ពេលខ្លួនរើរបងពុំមានអ្នកណាមកឃាត់នោះទេ ។ ខ្លួនកាន់កាប់នៅឆ្នាំ១៩៩២ មានមេភូមិទទួលស្គាល់ បច្ចុប្បន្នខ្លួននៅតែកាន់កាប់ដីនេះដដែល ។ ខ្លួនមិនបានលក់ដីឱ្យឈ្មោះ [redacted] សេដ្ឋបុត្រ ទេ ខ្លួនគ្រាន់តែផ្ដិតមេដៃពឹងពាក់ឱ្យឪពុករបស់ឈ្មោះ [redacted] សេដ្ឋបុត្រ ទៅនិយាយជាមួយលោកឧកញ៉ា [redacted] ទ្រី ឱ្យដកពាក្យបណ្ដឹងដែលគាត់បានដាក់ពាក្យប្ដឹងហាមឃាត់មិនឱ្យចេញប័ណ្ណឱ្យប្រពន្ធខ្លួនតែប៉ុណ្ណោះ ។ ដីមានក្បាលទំហំ ៥៥ ម៉ែត្រ បណ្ដោយ ២០០ ម៉ែត្រ ប៉ុន្តែកំពុងប្ដឹងផ្ដល់ដីទំហំ ១៩ ម៉ែត្រ គុណនឹង ៣០ ម៉ែត្រ ប៉ុណ្ណោះ ដីផ្សេងពីនេះបានចែកឱ្យបងប្អូនអស់ហើយ នៅសល់តែ ១៩ម៉ែត្រ គុណនឹង ៣០ម៉ែត្រ ទុកខ្លួនឯង ដោយមានមេភូមិ និងសុរិយោដីចុះវាស់វែងធ្វើប្លង់ផងដែរ ។ ដីនេះមានក្បាលលេខ ១៥៩ ដោយខ្លួនបានធ្វើបង្គោលរបងស៊ីមង់បន្ទាលួសចំណែកឈ្មោះ [redacted] ដេង ធ្វើរបងថ្មពីជ្រុងខាងមុខ និងខាងកើត ។ ពេលខ្លួនធ្វើរបងលួសធ្វើជាបីជ្រុង ។ ដីរបស់ឈ្មោះ [redacted] ឌិន នៅកន្លែងផ្សេងនោះទេ ចំណែកឈ្មោះ ឈិន សេដ្ឋបុត្រ ពុំមានដីនៅទីនេះទេ ។ ដោយសារតែឈ្មោះ [redacted] ទ្រី ប្ដឹងទើបគេមិនចេញប្លង់ឱ្យ ហើយដីនេះបានដាក់រក្សាការពាររួចហើយ ។

*២.១.២ ជនជាប់ចោទឈ្មោះ [redacted] ជី បានឆ្លើយថា: ខ្លួនអើរបងទុកមួយជុំ រួចដើមបណ្តឹងរដ្ឋប្បវេណីទៅថតយកមកប្តឹងខ្លួន ។ ដីនេះខ្លួនបានកាន់កាប់តាំងពីឆ្នាំ ១៩៩២ មកម្ល៉េះ ហើយរបងខ្លួនក៏ធ្វើនៅឆ្នាំ១៩៩២ ដែរ បន្ទារលួសបង្គោលមានប្រវែង ១ម៉ែត្រដាង ។ ឈ្មោះ [redacted] ឌិន ទៅធ្វើរបងពីខាងក្នុងរបងខ្លួន ។ ខ្លួនចូលកាន់កាប់ដីនេះ តាំងពីឆ្នាំ ១៩៩២ ដីនេះខ្លួនមិនបានលក់ឱ្យឈ្មោះ [redacted] សេដ្ឋបុត្រ នោះទេ ។ ដីនេះ ពុំមានទំនាស់ជាមួយអ្នកផ្សេងទេ តែលោកឧកញ៉ា [redacted] ទ្រីវ ប្តឹងមិនឱ្យចេញប្លង់ ។ ដីនេះ មានប្រធានភូមិជាអ្នកដឹងឮផងដែរ ។*

**២.២ ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី:**

*២.២.១. តុលាការបង្គាប់ឱ្យក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឌិន នៅដំណាក់កាលចៅក្រមស៊ើបសួរ ដែលមានខ្លឹមសារថា:* ចំពោះដីនេះខ្លួនបានចូលមករស់នៅតាំងពីឆ្នាំ១៩៩៣ មកម្ល៉េះ ដោយពេលនោះដីមានទំហំ ៤៨ម៉ែត្រ គុណ ២០០ម៉ែត្រ ប៉ុន្តែដីនេះត្រូវបានឈ្មោះ [redacted] ដេង ដែលត្រូវជាប្អូនប្រុសរបស់ខ្លួន យកទៅលក់ឱ្យអ្នកដទៃអស់មួយចំនួន ហើយបច្ចុប្បន្នដីនេះនៅសល់តែទំហំ៤៨ម៉ែត្រ គុណ ១០០ម៉ែត្រ គឺមានអាជ្ញាធរទទួលស្គាល់ដឹងឮ ដូចមាននៅក្នុងលិខិតបញ្ជាក់ប្រវត្តិដី និងផ្ទះ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៦ ដែលទទួលស្គាល់ដោយលោកមេភូមិ [redacted]រ៉ុង និងចៅសង្កាត់ [redacted] សារុន ស្រាប់ ។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៦ ឈ្មោះ [redacted] ដេង និងឈ្មោះ ប៉ង់ ជី បានចូលទៅរុះអើរបងអស់ ៣០ដើម ហើយពេលនោះខ្លួនបានចូលទៅឃាត់ដែរ តែពួកគេមិនស្តាប់។ សំណូមពរសូមឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមផ្លូវច្បាប់ ។

*២.២.២. តុលាការបង្គាប់ឱ្យក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សេដ្ឋបុត្រ នៅដំណាក់កាលចៅក្រមស៊ើបសួរ ដែលមានខ្លឹមសារថា:* ចំពោះដីនេះខ្លួនបានទទួលសិទ្ធិពីឈ្មោះ [redacted] ដេង តាមរយៈកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៥ ក្នុងទំហំដី ១០មែត្រ គុណនឹង ៣០ម៉ែត្រ ចំណែកដីទំហំ ១០ម៉ែត្រ គុណនឹង ៣០ម៉ែត្រទៀត ខ្លួនបានទិញពីឈ្មោះ [redacted]រ៉ុង តាមកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ។ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ឈ្មោះ [redacted] ដេង ឈ្មោះ [redacted] ជី រួមជាមួយនឹងកម្មករ បានចូលមករុញបង្គោលរបង និងដកក្រវ៉ៃងបង្គោលចោល ហើយនៅពេលនោះខ្លួនបានទៅឃាត់ពួកគាត់ ប៉ុន្តែពួកគាត់មិនព្រមឈប់ ។ ខ្លួនសំណូមពរទាមទារសំណងការខូចខាតចំនួន ៥០,០០០ ដុល្លារអាមេរិក និងស្នើសុំឱ្យផ្តន្ទាទោសលើឈ្មោះ [redacted] ដេង និងឈ្មោះ [redacted]ជី ទៅតាមផ្លូវច្បាប់ ។

**២.៣ ការស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ:** *កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៦ និងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ពិតជាមានសកម្មភាព រំលោភកាន់កាប់អចលនវត្ថុអ្នកដទៃ បង្កដោយឈ្មោះ [redacted]ដង និងឈ្មោះ បង់ ជី ប្រាកដមែន ដូច្នេះតំណាងអយ្យការស្នើសុំតម្កល់ការចោទប្រកាន់ទុកជាបានការដដែល និងសុំឱ្យផ្តន្ទាទោសជនល្មើសតាមច្បាប់ ។*



Scanned with CamScanner

**២.៤ ការស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ការពារសិទ្ធិជនជាប់ចោទ:** ឈ្មោះ [redacted] ដេង និង ឈ្មោះ [redacted] ធី បានកាន់កាប់ដីនេះតាំងពីឆ្នាំ ១៩៩២ មកម្ល៉េះ ហើយអជ្ញាធរក៏បានចេញបង្កាន់ដៃឱ្យផងដែរ រួចហើយឈ្មោះ [redacted] ទ្រីវ បានប្តឹងជំទាស់មិនឱ្យសុរិយោដីចេញប្លង់បន្ទាប់មក កូនក្តីខ្លួនក៏បានពឹងពាក់ឪពុករបស់ឈ្មោះ [redacted] សេដ្ឋបុត្រ និងអ្នកផ្សេងទៀតឱ្យជួយនិយាយជាមួយឈ្មោះ [redacted] ទ្រីវ ដើម្បីឱ្យគាត់ដកពាក្យបណ្តឹង ដោយសារគ្មានលុយក៏ធ្វើលិខិតផ្ទេរដីឱ្យទៅ ។ នៅអំឡុងឆ្នាំ២០១៤ ឈ្មោះ [redacted] ធី ក៏បានប្តឹងឈ្មោះ [redacted] ទ្រីវ វិញ ទៅសភាស៊ើបសួរ ហើយឈ្មោះ [redacted] សឿន ក៏បានប្តឹងក្បាលដីលេខ ១២០ ទៅក្រសួងមហាផ្ទៃផងដែរ បន្ទាប់មកនគរបាលព្រហ្មទណ្ឌមហាផ្ទៃក៏បានចុះអង្កេត និងវាស់វែងរួចមកឈ្មោះ [redacted] សឿន ក៏ឈប់ប្តឹងវិញ ដោយដឹងថាមានដីពិតប្រាកដមែន ។ រហូតដល់ឆ្នាំ២០១៥ កូនក្តីខ្លួនក៏ពឹងគេឱ្យទៅនិយាយជាមួយឈ្មោះ [redacted] ទ្រីវ ឱ្យដកពាក្យបណ្តឹងវិញ ដោយធ្វើលិខិតលក់ផ្តាច់ឱ្យដី ។ កូនក្តីខ្លួន បានដាក់រក្សាការពារលើដីនោះ រួចមកសហកូនបំណុលក៏បានវាយរបង ហើយកូនក្តីខ្លួនដាក់បណ្តឹងព្រហ្មទណ្ឌពីបទ មិនគោរពតាមសេចក្តីសម្រេចរបស់តុលាការ រួចហើយតុលាការក៏បានផ្តន្ទាទោសជនល្មើសដែលត្រូវជាដើមបណ្តឹងក្នុងរឿងនេះផងដែរ ។ កូនក្តីខ្លួន ពិតជាមានបង្កាន់ដៃដីប្រាកដមែន ដូច្នេះស្នើសុំតុលាការពិចារណាឱ្យកូនក្តីខ្លួនរួចផុតបទចោទប្រកាន់ផង ។

**២.៥ ការស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ:** ខ្លួនបានដាក់ភស្តុតាងរួចហើយ ការដែលដើមបណ្តឹងរដ្ឋប្បវេណីគាត់មានលិខិតលក់ផ្តាច់ គឺកូនក្តីខ្លួនបានសុំឱ្យជួយនិយាយជាមួយឈ្មោះ [redacted] ទ្រីវ ដើម្បីឱ្យដកពាក្យបណ្តឹងដែលឧកញ៉ា [redacted] ទ្រីវ ដាក់ហាមឃាត់កុំឱ្យចេញប័ណ្ណ រួចក៏បានសន្យាឱ្យដីដោយបានធ្វើលិខិតលក់ផ្តាច់ ហើយនៅក្នុងលិខិតលក់ផ្តាច់គឺជាការរៀបចំរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដោយតំលៃនិងព្រំប្រទល់មិនបានសរសេរច្បាស់លាស់ទេ បើជាការទិញលក់ដី គឺមានលិខិតទិញលក់ដីហើយ ។ ដីរបស់ឈ្មោះ [redacted] ឌិន ពុំមាននោះទេ ចំណែកដីរបស់ឈ្មោះ សេដ្ឋបុត្រ ក៏ពុំមាននៅទីនេះដែរ ។ ដីកូនខ្លួនមានតែ ១៩ម៉ែត្រ គុណនឹង ៣០ម៉ែត្រ ប៉ុណ្ណោះ តើមានដីឯណាដូចដើមបណ្តឹងបានអះអាង ដូច្នេះសុំបដិសេធភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដាក់ជូនតុលាការ ។

**២.៦ ការស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ:** ឈ្មោះ [redacted] ដេង និងប្រពន្ធឈ្មោះ [redacted] ធី បានកាន់កាប់ដីនេះតាំងពីឆ្នាំ១៩៩២ ហើយដោយសារឈ្មោះ [redacted] ដេង ទៅកោះកុង កូនក្តីខ្លួនឈ្មោះ [redacted] ធី ក៏បានដាក់ឈ្មោះ គាត់ និងបងប្រុសរបស់គាត់ ហើយដីនេះបានចេញបង្កាន់ដៃក្បាលដីជាតំបន់វិនិច្ឆ័យហើយ ធ្វើម៉េចនឹងអាចចេញប្លង់ទុនបាន ។ កូនក្តីខ្លួនបានដាក់រក្សាការពារហាមកុំឱ្យធ្វើអ្វីនៅលើដីនោះ តែគាត់ម្ខាងទៀតជាអ្នកមិនគោរព រួចហើយកូនក្តីខ្លួនក៏បានដាក់បណ្តឹងព្រហ្មទណ្ឌ ហើយតុលាការក៏បានសម្រេចផ្តន្ទាទោសដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ហើយដើមបណ្តឹងរដ្ឋប្បវេណីក៏បានប្តឹង

ឧទ្ទរណ៍ បច្ចុប្បន្នបានចូលជាស្ថាពរហើយ ដូច្នេះស្នើសុំតុលាការឱ្យកូនក្តីខ្លួនរួចផុតបទចោទប្រកាន់ផង ។

២.៧ **ការស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ:** សុំតុលាការជួយរកយុត្តិធម៌ និងលើកលែងការចោទប្រកាន់ឱ្យពួកខ្លួនផង ។

## ៣.ផ្នែកសំអាងហេតុ

## ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ សាលាដំបូងខេត្តព្រះសីហនុ យល់ឃើញថា៖

៣.១ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ:២៣២៨ តព/២១ ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០២១[1] ចៅក្រមស៊ើបសួរបានសម្រេចប្តឹងចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ដេង ភេទប្រុស កើតឆ្នាំ១៩៦៤ និងឈ្មោះ [redacted] ធី ភេទស្រី ជនជាតិខ្មែរ មកជំនុំជម្រះពីបទ: ធ្វើឱ្យខូចខាតដោយចេតនា និងបទ រំលោភកាន់កាប់អចលនវត្ថុអ្នកដទៃ ប្រព្រឹត្តនៅចំណុចភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៦ និងថ្ងៃទី១១ ខែធ្នូ ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

៣.២ អំពើល្មើសដែលរងការចោទប្រកាន់ត្រូវបានប្រព្រឹត្តកាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០១៦ ជាអំពើស្ថិតក្នុងវិសាលភាព នៃក្រមព្រហ្មទណ្ឌ និងច្បាប់ភូមិបាល ។

៣.៣ យោងតាមលទ្ធផលនៃការសួរដេញដោល និងពិនិត្យមើលភស្តុតាងនានានៅក្នុងសំណុំរឿង តុលាការពិចារណាឃើញថា ពុំមានភស្តុតាងគ្រាប់គ្រាន់ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ដេង និងឈ្មោះ [redacted] ធី ពីបទ ធ្វើឱ្យខូចខាតដោយចេតនា និងបទ រំលោភកាន់កាប់អចលនវត្ថុ នោះទេ ដោយហេតុថា៖

- ផ្អែកតាមចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់ខាងលើ បានឆ្លើយបញ្ជាក់ថា ពួកខ្លួនពិតជាបានដករបងបង្គោលមែន ប៉ុន្តែរបងបង្គោលនោះ គឺជារបងបង្គោលលើដីរបស់ខ្លួន ដែលខ្លួនកាន់កាប់ដីនោះតាំងពីឆ្នាំ ១៩៩២ មកម្ល៉េះ ដោយដំបូងឡើយខ្លួនធ្វើបង្គោលរបងឈើ បន្ទាប់មកធ្វើរបងបង្គោលស៊ីម៉ង់វិញ ពួកខ្លួនមិនបានដករបងបង្គោលលើដីអ្នកផ្សេងឡើយ ។ ចំពោះចម្លើយនេះ មានភាពស៊ីសង្វាក់ទៅនឹងរបងបង្គោលចាស់ៗដែលគេបានដកផ្តួលចោលនៅក្នុងរូបថតប្រាកដមែន ។
- តាមភស្តុតាងដែលផ្តល់ដោយជនជាប់ចោទបង្ហាញឱ្យឃើញថា នៅក្នុងឆ្នាំ២០០៧ ជនជាប់ចោទបានទទួលបង្កាន់ដៃប្តូរជាប្រព័ន្ធរួចហើយ គឺ

[1] ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ:២៣២៨ តព/២១ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ របស់នៃសាលាដំបូងខេត្តព្រះសីហនុ ។ (ឯកសារលេខ:១១/៣)



Scanned with CamScanner

លេខ ១៦១ និងលេខ ៣៩៩ ប៉ុន្តែអាជ្ញាធរសុរិយោដីមិនអាចចេញវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុឱ្យជនជាប់ចោទបាន ដោយសារ លោកឧកញ៉ា [redacted] ទ្រីវ បានប្ដឹងហាមឃាត់ ចំណុចនេះបញ្ជាក់ថា អចលនវត្ថុនេះគឺជាកម្មសិទ្ធិរបស់ជនជាប់ចោទ ចំណែកលិខិតលក់ផ្ដាច់ដែលឈ្មោះ [redacted] ដេង ផ្តិតមេដៃជាមួយឈ្មោះ [redacted] សាយ , ឈ្មោះ [redacted] វ៉ុង នោះ ពុំអាចទទួលយកជាកស្តុតាងបានឡើយ ព្រោះពុំមានលក្ខណៈគតិយុត្តិ ដោយហេតុថា ពុំមានអាជ្ញាធរដីធ្លីលើលិខិតលក់ផ្ដាច់នេះឡើយ ចំណុចនេះបញ្ជាក់ថា ដីនេះពុំមែនជាកម្មសិទ្ធិរបស់ដើមបណ្ដឹងទេ ។

- យោងតាមកស្តុតាងដែលដើមបណ្ដឹងរដ្ឋប្បវេណីដាក់ជូនតុលាការពិនិត្យឃើញថា ពុំមានភាពច្បាស់លាស់នោះទេ ដោយកិច្ចសន្យាលក់ផ្ដាច់មួយចំនួន ពុំមានហត្ថលេខាដីធ្លីពីអាជ្ញាធរមានសមត្ថកិច្ចឡើយ យ៉ាងណាមិញ ផ្អែកតាមចម្លើយជនជាប់ចោទបានបញ្ជាក់យ៉ាងច្បាស់ថា ដីរបស់ឈ្មោះ [redacted] ខិន នៅកន្លែងផ្សេង និងដីរបស់ឈ្មោះ [redacted] សេដ្ឋបុត្រ ក៏ពុំមាននៅទីនេះដែរ ដូច្នេះផ្អែកតាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[2] ក៏បានបញ្ញត្តិដែរថា " **ប្រសិនបើតុលាការយល់ឃើញថា អំពើនោះមិនមែនជាបទល្មើសទេ ឬ ក៏ជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ** " ។
- អំពើដែលឈ្មោះ [redacted] ដេង និងឈ្មោះ [redacted] ជី ចូលទៅរុះបង្គោលប្ដូរពីបង្គោលរបងលួសឈើ មកដាក់ជាបង្គោលរបងលួសស៊ីម៉ង់ត៍វិញ ហើយធ្វើនៅអចលនវត្ថុដែលជាកម្មសិទ្ធិផ្ទាល់របស់ខ្លួន ពុំមែនជាបទល្មើសធ្វើឱ្យខូចខាតដោយចេតនា និងរំលោភកាន់កាប់អចលនវត្ថុរបស់អ្នកដទៃឡើយ ។

៣.៤ យោងតាមសំអាងហេតុខាងលើ បានបង្ហាញឱ្យឃើញថា គ្មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ដេង និងឈ្មោះ [redacted] ជី ពីបទ**ធ្វើឱ្យខូចខាតដោយចេតនា និងបទ រំលោភកាន់កាប់អចលនវត្ថុអ្នកដទៃ** ប្រព្រឹត្តនៅភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៦ និងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៥៣ នៃច្បាប់ភូមិបាលទេ ។

[2] មាត្រាពាក់ព័ន្ធ: មាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣.៥ តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា សុំតម្កល់ការចោទប្រកាន់ទុកជាបានការដដែល និងសុំឱ្យផ្ដន្ទាទោសជនល្មើសតាមច្បាប់ ។ គប្បីតុលាការលើកយកមកពិចារណា ។

៣.៦ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា សុំតុលាការមេត្តាសម្រេចឱ្យកូនក្ដីពួកខ្លួនរួចផុតពីបទចោទប្រកាន់ផង ។ គប្បីតុលាការលើកយកមកពិចារណា ។

៣.៧ ជនជាប់ចោទបាននិយាយសំដីចុងក្រោយថា សុំតុលាការជួយរកយុត្តិធម៌ និងលើកលែងការចោទប្រកាន់ឱ្យពួកខ្លួនផង ។ គប្បីតុលាការលើកយកមកពិចារណា ។

## ៤.ផ្នែកសេចក្ដីសម្រេច ៖

## ហេតុដូច្នេះសាលាដំបូងខេត្តព្រះសីហនុ

## វិនិច្ឆ័យសេចក្ដី

៤.១ **ឱ្យរួចខ្លួនពីបទចោទលើ**ឈ្មោះ [redacted] **ដេង** ភេទប្រុស កើតឆ្នាំ១៩៦៥ ជនជាតិខ្មែរ និងឈ្មោះ [redacted] **ធី** ភេទស្រី អាយុ ៥៧ឆ្នាំ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) ប្រព្រឹត្តនៅភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៦ និងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**សាលក្រម** នេះជំនុំជម្រះនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី ។ ទុកសិទ្ធិឱ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា: [redacted]

---

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]

“បានចម្លងត្រឹមត្រូវតាមច្បាប់ដើម”
ថ្ងៃអង្គារ ៧កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ខេត្តព្រះសីហនុ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២
**ក្រឡាបញ្ជី**
[redacted]